លេខ ៣១ ចេញផ្សាយថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែធ្នូ ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃសុក្រ ៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ បាន សហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការ អភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃ និយ័តករបរធនបាលកិច្ច និង **បណ្ឌិត មាន សុធី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ នៅសាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាប ការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការ បរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យ បរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិត ដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែន ធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងនិស្សិត នៃសាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ។

## មាតិកា


- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី១
- កិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី២
- កិច្ចប្រជុំបរធនបាលកិច្ចឆ្នាំ២០២៣ ទំព័រទី២
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៣
- សិក្ខាសាលាស្តីពី "ការដោះស្រាយគម្រោងវិនិយោគជាប់គាំង និងយន្តការបរធនបាលកិច្ច" ទំព័រទី៣
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៣
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែធ្នូ ឆ្នាំ២០២៣ ទំព័រទី៤
- កិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងប្រកាសស្តីពី ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច និងសេចក្តីព្រាងប្រកាសស្តីពី ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច ទំព័រទី៤
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៥
- សិក្ខាសាលាស្តីពី ស្តីពី "ការឆ្លុះបញ្ចាំងលទ្ធផលការងារសម្រេចបានឆ្នាំ២០២៣" ទំព័រទី៥
- កិច្ចប្រជុំដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាឆ្នាំ២០២៤ ទំព័រទី៦
- កិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ទំព័រទី៦
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៦
- វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញមុខងារជានគរបាលយុត្តិធម៌ និងនីតិវិធីពាក់ព័ន្ធនានា" ទំព័រទី៧
- កិច្ចប្រជុំកម្រិតអន្តរអគ្គនាយកដ្ឋាន ដើម្បីពិនិត្យលើការរៀបចំឯកសារវិភាគមុខងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី៧
- សិក្ខាសាលាស្តីពី "អនុលោមភាពនៃការវាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច" ទំព័រទី៨
- កិច្ចកិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "ការចុះត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនបរធនបាល" ទំព័រទី៨
  វគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពី "ទ្រព្យសម្បត្តិបរធនបាលកិច្ច" ទំព័រទី៩
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១៦ ទំព័រទី៩
- សិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី១០




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

ព្រឹកថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាគល** អគ្គនាយករង, **លោក ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និង **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការនៃ **ន.ប.ធ.** បានដឹកនាំសហការី ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីពិភាក្សាលើលទ្ធផលការងារសម្រេចបានរបស់ **ន.ប.ធ.** នៅក្នុងឆ្នាំ២០២៣។

កិច្ចប្រជុំនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងកិច្ចសហការខ្ពស់។



រូបភាព៖ កិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កិច្ចប្រជុំបរធនបាលកិច្ចឆ្នាំ២០២៣

នារសៀលថ្ងៃអង្គារ ៨រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធី "កិច្ចប្រជុំបរធនបាលកិច្ចឆ្នាំ២០២៣" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាន ព្រមទាំងមន្ត្រីជំនាញនៃ **ន.ប.ធ.** ដែលមានការចូលរួមពីក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ដើម្បីពិនិត្យរួមគ្នាអំពីវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា ដល់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធ ដើម្បីពិភាក្សាក៏ដូចជាឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅពីបញ្ហាប្រឈមនានាក្នុងការអនុវត្តការងារគ្រប់គ្រងបរធនបាលកិច្ច ព្រមទាំងទទួលបានធាតុចូលអំពីទស្សនវិស័យចំពោះនិន្នាការនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ច និងសំណូមពរនានាពីប្រតិបត្តិករនៅក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា នៅទីស្តីការរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

កម្មវិធីនេះត្រូវបានបញ្ចប់ទៅដោយរលូន និងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។




រូបភាព៖ កិច្ចប្រជុំបរធនបាលកិច្ចឆ្នាំ២០២៣។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃពុធ ៩រោច ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្ដម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្ដីព្រាងផែនការសកម្មភាពបីឆ្នាំរំកិល ២០២៣-២០២៥ របស់និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

## សិក្ខាសាលាស្ដីពី "ការដោះស្រាយគម្រោងវិនិយោគជាប់គាំង និង យន្ដការបរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយក្រុមការងារដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ និងរដ្ឋបាលខេត្តព្រះសីហនុ បានរៀបចំសិក្ខាសាលាស្ដីពី "ការដោះស្រាយគម្រោងវិនិយោគជាប់គាំង និង យន្ដការបរធនបាលកិច្ច" ដល់រដ្ឋបាលសាលាខេត្ត ធុរជនជាតិ និងបរទេស និងបុគ្គលពាក់ព័ន្ធនៅសណ្ឋាគារ Sea Breeze Hotel & Villa ខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដម ពេជ្រ សម្បត្តិ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមការងារដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ, **ឯកឧត្ដម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក ម៉ាង ស៊ីណែត** អភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលដៅដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមអំពីបរធនបាលកិច្ច ដែលជាផ្នែកមួយនៃដំណោះស្រាយក្នុង "វិធានការជាកញ្ចប់របស់រាជរដ្ឋាភិបាលសម្រាប់ដំណោះស្រាយគម្រោងជាប់គាំងក្នុងខេត្តព្រះសីហនុ" ដែលមានសមាសភាពអញ្ជើញចូលរួមពីតំណាងជាន់ខ្ពស់នៃក្រសួង/ស្ថាប័នពាក់ព័ន្ធ, រដ្ឋបាលខេត្តព្រះសីហនុ, សភាពាណិជ្ជកម្មខេត្តព្រះសីហនុ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.**, តំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ សមាគមវិនិយោគិនចិន និងសមាគមធុរកិច្ចពាក់ព័ន្ធ។



រូបភាព៖ សិក្ខាសាលាស្ដីពី "ការដោះស្រាយគម្រោងវិនិយោគជាប់គាំង និង យន្ដការបរធនបាលកិច្ច"។

## សិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

ព្រឹកថ្ងៃសុក្រ ១១រោច ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យបៀលប្រាយបានសហការគ្នារៀបចំសិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដម ណឹ សាគល** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច និង **លោកស្រី សេខ សុតា** នាយិកាសាខានៃសាកលវិទ្យាល័យបៀលប្រាយ (ខេត្តព្រះសីហនុ) នៅសាកលវិទ្យាល័យបៀលប្រាយ (ខេត្តព្រះសីហនុ)។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងនិស្សិត នៃសាកលវិទ្យាល័យបៀលប្រាយ (ខេត្តព្រះសីហនុ)។




**រូបភាព៖** សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែធ្នូ ឆ្នាំ២០២៣

រសៀលថ្ងៃចន្ទ ១៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែធ្នូ ឆ្នាំ២០២៣ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោក/កញ្ញាប្រធាននាយកដ្ឋាន ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់សមិទ្ធផលការងារដែលសម្រេចបានក្នុងខែវិច្ឆិកា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។




**រូបភាព៖** កិច្ចប្រជុំបូកសរុបការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែធ្នូ ឆ្នាំ២០២៣។

## កិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងប្រកាសស្តីពី ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច និងសេចក្តីព្រាងប្រកាសស្តីពី ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច

នាព្រឹកថ្ងៃអង្គារ ១៥រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងប្រកាសស្តីពី ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច និងសេចក្តីព្រាងប្រកាសស្តីពី ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃ **ន.ប.ធ.** រួមមាន ឯកឧត្តមអគ្គនាយករង លោក-កញ្ញាប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញនៃ **ន.ប.ធ.**។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងទទួលបានមតិយោបល់ និងធាតុចូលបន្ថែមពីមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីឱ្យសេចក្តីព្រាងប្រកាសនេះកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ។



**រូបភាព៖** កិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងប្រកាសស្តីពី ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច និងសេចក្តីព្រាងប្រកាសស្តីពី ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

រសៀលថ្ងៃព្រហស្បតិ៍ ២កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី វិធាននិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណរបស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## សិក្ខាសាលាស្តីពី ស្តីពី "ការឆ្លុះបញ្ចាំងលទ្ធផលការងារសម្រេចបានឆ្នាំ២០២៣"

នាព្រឹកថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំសិក្ខាសាលាស្តីពី "ការឆ្លុះបញ្ចាំងលទ្ធផលការងារសម្រេចបានឆ្នាំ២០២៣" នៃគម្រោង ACSEP សមាសភាគទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1 អមដោយ **លោកស្រី** Marishka Etrata តំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងប្រធានផ្នែកនៃគម្រោង ACSEP PIU1 នៅសណ្ឋាគារ សុខា រាជធានីភ្នំពេញ។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីស្តាប់នូវរបាយការណ៍ និងបញ្ហាប្រឈម ព្រមទាំងសំណូមពរនានារបស់អង្គភាពពាក់ព័ន្ធ ជាពិសេសស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ ក្នុងដំណើរការអនុវត្តគម្រោងពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការផ្នែកឥណទានក្នុងឆ្នាំ២០២៣ ដើម្បីឈានទៅរកដំណោះស្រាយសមស្របរួមគ្នាមួយសម្រាប់ការរៀបចំយុទ្ធសាស្ត្រអនុវត្ត ឱ្យបានល្អប្រសើរជាងនេះ សម្រាប់ឆ្នាំ២០២៤។

សិក្ខាសាលានេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមកពីអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ **ក.ស.ហ.វ.**, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។





រូបភាព៖ សិក្ខាសាលាស្តីពី ស្តីពី "ការឆ្លុះបញ្ចាំងលទ្ធផលការងារសម្រេចបានឆ្នាំ២០២៣"។

## កិច្ចប្រជុំដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំផែនការ ថវិកាឆ្នាំ២០២៤

នារសៀលថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វិសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានចូលរួមក្នុងកិច្ចប្រជុំដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាឆ្នាំ២០២៤ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខា-ធិការដ្ឋាន **អ.ស.ហ.** ដោយមានការចូលរួមពីឯកឧត្តមប្រតិភូ ឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ កិច្ចប្រជុំដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាឆ្នាំ២០២៤។

## កិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ

នាព្រឹកថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើឯកសារនៃសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ កិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ **លោក ប៉ុ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និង **លោក ណង សេរីវុធ** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះ-បណ្តាល និងសហប្រតិបត្តិការ អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារសេចក្តីព្រាងនៃផែនការអភិវឌ្ឍន៍ស្ថាប័ននិយ័តករធានារ៉ាប់រងកម្ពុជាសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) និងផែនការអភិវឌ្ឍន៍ស្ថាប័នអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

## វគ្គបណ្តុះបណ្តាលស្តីពី “ការបំពេញមុខងារជានគរបាលយុត្តិធម៌ និងនីតិវិធីពាក់ព័ន្ធនានា”

ព្រឹកថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយក្រសួងយុត្តិធម៌ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី “ការបំពេញមុខងារជានគរបាលយុត្តិធម៌ និងនីតិវិធីពាក់ព័ន្ធនានា” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងតំណាងរបស់ក្រសួងយុត្តិធម៌, **ឯកឧត្តម នុប សុធនវិសុទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងអមដោយ **លោកជំទាវ ប៉ែន ផល្លីការ** ប្រធាននាយកដ្ឋានយុត្តិធម៌ព្រហ្មទណ្ឌ និងនគរបាលយុត្តិធម៌ និងសហការី ព្រមទាំងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់ **ន.ប.ធ.** និងមន្ត្រីអធិការកិច្ចបរធនបាលកិច្ចដែលទទួលបាននីតិសម្បទានជានគរបាលយុត្តិធម៌ និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀតរបស់ **ន.ប.ធ.** និងតំណាងក្រសួងយុត្តិធម៌។

វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិអំណាចរបស់មន្ត្រីអធិការកិច្ចបរធន-បាលកិច្ច ក្នុងការស៊ើបអង្កេត ត្រួតពិនិត្យ ស្រាវជ្រាវបទល្មើសឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ ចាប់វិធានការផ្អាកសកម្មភាពអាជីវកម្មជាបណ្តោះអាសន្ន ព្រមទាំងអនុវត្តតួនាទីនៃការធ្វើអធិការកិច្ចក្នុងវិស័យបរធនបាលកិច្ច ប្រកបដោយវិជ្ជាជីវៈប្រសិទ្ធភាព និងសណ្តាប់ធ្នាប់របៀបរៀបរយ។



រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី “ការបំពេញមុខងារជានគរបាលយុត្តិធម៌ និងនីតិវិធីពាក់ព័ន្ធនានា” នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

## កិច្ចប្រជុំកម្រិតអន្តរអគ្គនាយកដ្ឋាន ដើម្បីពិនិត្យលើការរៀបចំឯកសារវិភាគមុខងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រឹកថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និង **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតអន្តរអគ្គនាយកដ្ឋាន ដើម្បីពិនិត្យលើការរៀបចំឯកសារវិភាគមុខងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងពង្រឹងការអនុវត្តមុខងារស្ថាប័នឱ្យមានសង្គតិភាព និងប្រើប្រាស់ធនធានប្រកប-ដោយប្រសិទ្ធភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មាស សុខសេនសាន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយផ្ទាល់ពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



រូបភាព៖ កិច្ចប្រជុំកម្រិតអន្តរអគ្គនាយកដ្ឋាន ដើម្បីពិនិត្យលើការរៀបចំឯកសារវិភាគមុខងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សិក្ខាសាលាស្តីពី "អនុលោមភាពនៃការវាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ១០កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាស្តីពី "អនុលោមភាពនៃការវាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច" នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងការវាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច ឱ្យកាន់តែមានសុក្រឹត្យភាព តម្លាភាព និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដែលអាចផ្តល់នូវទំនុកចិត្តបន្ថែមទៀតដល់វិនិយោគិន ឬបរធនបាលទាយក ឬម្ចាស់ទ្រព្យ។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ចទាំងអស់ដែលទទួលបានការទទួលស្គាល់ពី **ន.ប.ធ.**។ កម្មវិធីនេះត្រូវបានបញ្ចប់ទៅដោយរលូន និងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។



រូបភាព៖ សិក្ខាសាលាស្តីពី "អនុលោមភាពនៃការវាយតម្លៃទ្រព្យសម្បត្តិបរធនបាលកិច្ច"។

## កិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "ការចុះត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនបរធនបាល"

នារសៀលថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "ការចុះ-ត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនបរធនបាល" ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃ **ន.ប.ធ.** រួមមាន ឯកឧត្តមអគ្គនាយករង លោក-កញ្ញាប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញនៃ **ន.ប.ធ.**។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងទទួលបានមតិយោបល់ និងធាតុចូលបន្ថែមពីមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីឱ្យសេចក្តីព្រាងសេចក្តីព្រាងគោលការណ៍ណែនាំនេះ កាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



**រូបភាព៖** កិច្ចប្រជុំអន្តរនាយកដ្ឋានលើសេចក្តីព្រាងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "ការចុះត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនបរធនបាល"។

## វគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពី "ទ្រព្យសម្បត្តិបរធនបាលកិច្ច"

ព្រឹកថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (ន.ប.ធ.) បានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពី "ទ្រព្យសម្បត្តិបរធនបាលកិច្ច" ដែលធ្វើបទបង្ហាញដោយ **លោក រិន រដ្ឋា** អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញនៃ **ន.ប.ធ.**។ វគ្គបណ្តុះបណ្តាលផ្ទៃក្នុងនេះ ការមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.**។



**រូបភាព៖** វគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពី "ទ្រព្យសម្បត្តិបរធនបាលកិច្ច"។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១៦

នាព្រឹកថ្ងៃព្រហស្បតិ៍ ១រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងមានការចូលរួមពីឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ឯកឧត្តមអគ្គនាយកនិយ័តករក្រោមឱវាទនៃ **អ.ស.ហ.** និងសមាជិក-សមាជិកា **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃនិយ័តករនិងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ដោយផ្ទាល់នៅទីស្តីការ **អ.ស.ហ.**។

ជាលទ្ធផលនៃកិច្ចប្រជុំ របៀបវារៈចំនួនពីររបស់ **ន.ប.ធ.** បានទទួលការអនុម័តពីអង្គប្រជុំ ដែលក្នុងនោះមាន ៖ (១). សេចក្តីព្រាងប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច និង (២). សេចក្តីព្រាងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ ដោយត្រូវធ្វើការកែសម្រួលលើទម្រង់ និងអក្ខរាវិរុទ្ធបន្ថែមមួយចំនួនមុនដាក់ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ចុះហត្ថលេខាដាក់ឱ្យអនុវត្តជាផ្លូវការ។



**រូបភាព៖** កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១៦។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច"

ព្រឹកថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាន និងសហការីនៃ **ន.ប.ធ.** ដោយមានការចូលរួមពីតំណាងមកពីបរធនបាល, ក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, បុគ្គលថែរក្សាសុវត្ថិភាពបរធន, បុគ្គលថែរក្សាទ្រព្យសម្បត្តិជំនួស, បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលពាក់ព័ន្ធផ្សេងទៀត។

សិក្ខាសាលាផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពីការដាក់ឱ្យអនុវត្តជាផ្លូវការនូវគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" និងការពន្យល់ពីខ្លឹមសារ ក៏ដូចជាការអនុវត្តនានាដែលមាននៅក្នុងគោលការណ៍ណែនាំនេះ សំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីគ្រប់តួអង្គ និងអ្នកចូលរួមទាំងអស់នៅក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏មានការធ្វើបទបង្ហាញដោយ **លោក ចេស ចាន់ដេត** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ អំពីខ្លឹមសារជារួមដែលមាននៅក្នុងគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" នេះផងដែរ។





*រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច"។*



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888